ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# លទ្ធផលនៃការពិនិត្យការអនុវត្តចំណូលថវិកា ប្រចាំត្រីមាសទី២ ឆ្នាំ២០២៣
# របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## I-ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣

យោងតាមព្រះរាជក្រមលេខ នស/រកម/១២២២/០១២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ បានប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។ នៅក្នុងច្បាប់នេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគ្រោងចំណូលឆ្នាំ២០២៣ សរុបមានចំនួន៣៩ ៤៩០,៤ លានរៀល ក្នុងនោះ ៖

**(ក)-រដ្ឋបាលកណ្តាលៈ** បានគ្រោងចំណូលសរុបចំនួន៣៩ ៤៨៩ លានរៀល ចំណូលនេះរួមមាន ៖

(១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន២២ ៩០៧ លានរៀល ស្មើនឹង៥៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ (២)ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវាមានចំនួន១៤ ៧៨២ លានរៀល ស្មើនឹង៣៧,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ (៣)ចំណូលពីផាកពិន័យ និងការដាក់ទណ្ឌកម្មមានចំនួន១ ៨០០ លានរៀល ស្មើនឹង៤,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣។

**(ខ)-មន្ទីររាជធានី ខេត្តៈ** បានគ្រោងចំណូលសរុបចំនួន១,៤ លានរៀល ស្មើនឹង១០០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ចំណូលនេះបានពីការជួលដីទំនេរនៃផលទុនពីការជួលដីទំនេរ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ។

## II-លទ្ធផលសម្រេចបាន

ដោយអនុវត្តតាមច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ នៅក្នុងត្រីមាសទី២ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុវត្តប្រមូលចំណូលសរុបមានចំនួន១០ ៣២៨,០លានរៀល ស្មើនឹង២៧,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង១២២,១% ធៀបនឹងកម្មវិធីដែលបានដាក់ចេញក្នុងនោះ ៖

**(ក)-រដ្ឋបាលកណ្តាលៈ** អនុវត្តប្រមូលចំណូលសរុបចំនួន១០ ៣២៨, លានរៀល ស្មើនឹង២៧,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង១២២,១% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ចំណូលនេះរួមមានៈ

(១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន៦ ៣៥៣,៦ លានរៀល ស្មើនឹង៣០,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង២២៩,៨% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (២)ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវាមានចំនួន៣ ៦១៥,៦ លានរៀល ស្មើនឹង២៨,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង៨០,៩% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (៣)ចំណូលពីផាកពិន័យ និងការដាក់ទណ្ឌកម្មមានចំនួន២៧៧,៧ លានរៀល ស្មើនឹង៨,៤% ធៀបនឹង

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខៈ (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខៈ (៨៥៥) ២៣ ២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax: (855) 23-217 320

ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង២២,៧% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (៤)ផលហិរញ្ញវត្ថុ មានចំនួន៦៧,២ លានរៀល ដែលជាចំណូលបានមកពីការបង់សំណេសចំណាយបៀវត្ស និង(៥)ផលពិសេសផ្សេងៗ មានចំនួន១៣,៩ លានរៀល។

(**ខ**)-**មន្ទីររាជធានី ខេត្ត៖** មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ មិនទាន់បានអនុវត្តចំណូលពីការជួលដីទំនេរទេ។

**III-ទិសដៅអនុវត្តបន្ត**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្តខិតខំនិងជំរុញការប្រមូលចំណូលបង់ចូលថវិកាជាតិស្របទៅតាមកម្មវិធីចំណូលប្រចាំត្រីមាសទី៣ ឆ្នាំ២០២៣ ដែលមានទឹកប្រាក់សរុប៩ ៤៤៥,៧ លានរៀល។ បន្តអនុវត្តកិច្ចសម្របសម្រួល និងសហការជាមួយអង្គភាពប្រមូលចំណូល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការរៀបចំប្រកាសអន្តរក្រសួង និងឯកសារកែសម្រួលសេវាសាធារណៈ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**III-សេចក្តីសន្និដ្ឋាន**

សរុបសេចក្តីមកការអនុវត្តប្រមូលចំណូលប្រចាំត្រីមាសទី២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រេចបាន១២២,១% ធៀបទៅនឹងកម្មវិធីដែលបានដាក់ចេញ ពោលគឺលើសផែនការ២២,១% ករណីនេះបណ្តាលមកពីការអនុវត្តប្រមូលចំណូលថ្លៃឈ្នួលដីសម្បទានសេដ្ឋកិច្ចមានកំណើនខ្លាំងក្នុងត្រីមាសទី២ ពោលកើន២៤៩% ធៀបនឹងផែនការដាក់ចេញ ការបង់សំណេសចំណាយបៀវត្សក្នុងឆ្នាំចាស់ និងបានមកពីប្រាក់លម្អៀងដោះដូរទីតាំងដីការិយាល័យកសិកម្មស្រុកព្រះស្តេច នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រៃវែង។

ដូច្នេះដើម្បីអនុវត្តប្រមូលចំណូលឱ្យបានតាមផែនការឆ្នាំ២០២៣ អង្គភាពពាក់ព័ន្ធទទួលបន្ទុកប្រមូលចំណូលត្រូវបន្តការយកចិត្តទុកដាក់ក្នុងការប្រមូល និងបង់ចំណូលឱ្យបានទាន់ពេលវេលា គួបផ្សំនឹងប្រតិបត្តិតាមនីតិវិធីថ្មីៗពាក់ព័ន្ធការបង់ចំណូលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ថ្ងៃ សុក្រ ៣ រោច ខែ ទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០២៣

**រដ្ឋលេខាធិការ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត ឆេង គឹមស៊ុន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# លទ្ធផលនៃការពិនិត្យការអនុវត្តចំណាយថវិកា ប្រចាំត្រីមាសទី២ ឆ្នាំ២០២៣
# របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សេចក្តីផ្តើម

ឆ្នាំ២០២៣ គឺជាឆ្នាំទី៨ ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តថវិកាកម្មវិធីពេញលេញដោយឈរលើគោលបំណងគោលនយោបាយរួមមួយគឺ៖ "**ជំរុញកំណើនកសិកម្មប្រកបដោយភាពប្រកួតប្រជែង ផលិតផលមានគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានដី ព្រៃឈើ និងជលផល ប្រកបដោយចីរភាព**"។ ដើម្បីឈានទៅសម្រេចគោលបំណងនេះ ក្រសួងបានដាក់ចេញនូវយុទ្ធសាស្ត្រសម្រាប់អនុវត្តជាកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ទៅតាមផ្នែកជំនាញនៃអង្គភាពថវិកាទាំង៤៦អង្គភាព ក្នុងនោះថ្នាក់កណ្តាល មានចំនួន ២១ អង្គភាពថវិកា និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានចំនួន២៥ រាជធានី ខេត្ត។

## I-ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣

យោងតាមព្រះរាជក្រមលេខ នស/រកម/១២២២/០១២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ បានប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។ នៅក្នុងច្បាប់នេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគ្រោងចំណាយឆ្នាំ២០២៣ សរុបមានចំនួន២៨០ ៧៦៨ លានរៀល ក្នុងនោះ ៖

**(ក)-រដ្ឋបាលកណ្តាល៖** បានគ្រោងឥណចំណាយសរុបចំនួន១៧៩ ១៧៧ លានរៀល រួមមាន៖

- ឥណទានចំណាយថវិកាចរន្ត មានចំនួន ១៦៤ ១៧៧ លានរៀល
- ឥណទានចំណាយថវិកាមូលធន មានចំនួន ១៥ ០០០ លានរៀល

**(ខ)-មន្ទីររាជធានី ខេត្ត ៖** បានគ្រោងឥណទានចំណាយថវិកាចរន្តសរុបចំនួន១០១ ៥៩១ លានរៀល។

## II-លទ្ធផលសម្រេចបាន

ដោយអនុវត្តតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ នៅក្នុងត្រីមាសទី២ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុវត្តចំណាយតាមអាណត្តិបើកប្រាក់សរុបចំនួន៦៩ ៧៩០,៣ លានរៀល ស្មើនឹង៤៤,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង៩៦,៩% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ក្នុងនោះ៖ រដ្ឋបាលកណ្តាល អនុវត្តបានចំនួន ៣៦ ១០៥,១ លានរៀល ស្មើនឹង៣៦,៦% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង១០២,៤% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ រីឯមន្ទីររាជធានី ខេត្ត អនុវត្តបានចំនួន៣៣ ६៨៥,២ លានរៀល ស្មើនឹង៥១,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង៩១,៦% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax: (855) 23-217 320

**(ក)-រដ្ឋបាលកណ្ដាល៖**

ដោយពិនិត្យទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាឃើញថា ការអនុវត្តចំណាយតាមអាណត្តិបើកប្រាក់របស់រដ្ឋបាលកណ្ដាល (២១ អង្គភាពថវិកា) សម្រេចបានចំនួន៣៦ ១០៥,១ លានរៀល ដោយក្នុងនោះ (ក)ការទិញ (ជំពូក៦០) អនុវត្តបានចំនួន៤ ៥០០,៣ លានរៀល ស្មើនឹង២០,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង ១៦៨,៧% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ខ)សេវាកម្ម (ជំពូក៦១) អនុវត្តបានចំនួន៥ ៩៦៣,០ លានរៀល ស្មើនឹង ១៦,០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង៩០,៧% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (គ)បន្ទុកបុគ្គលិក (ជំពូក៦៤) អនុវត្តបានចំនួន១៨ ៨៦៣,០ លានរៀល ស្មើនឹង២៣,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង ៩៨,៨% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ឃ)ឧបត្ថម្ភធន (ជំពូក៦៥) អនុវត្តបានចំនួន៦ ៧៧៨,៨ លានរៀល ស្មើនឹង ២៧,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង៩៨,០% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ង)ចំណាយមូលធន (ជំពូក២១) មិនទាន់បានអនុវត្តនៅឡើយ។

ម្យ៉ាងវិញទៀត ដោយពិនិត្យលើចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិការបស់អង្គភាពរដ្ឋបាលកណ្ដាល ឃើញថា ទឹកប្រាក់សរុបចំនួន៣៦ ១០៥,១ លានរៀល នេះត្រូវបានអនុវត្តចំណាយសម្រាប់ ៖

(១) ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច (កម្មវិធីទី១) ចំនួន៦ ២៩៧,៨ លានរៀល ស្មើនឹង២៤,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣

(២) ការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ (កម្មវិធីទី២) ចំនួន១ ៧២២,៣ លានរៀល ស្មើនឹង ២២,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣

(៣) ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម (កម្មវិធីទី៣) ចំនួន១ ៨១៩,៥ លានរៀល ស្មើនឹង ២៥,០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣

(៤) ការគ្រប់គ្រងនិងអភិវឌ្ឍធនធានព្រៃឈើ និងសត្វព្រៃ (កម្មវិធីទី៤) ចំនួន១ ៣៩៣,១ លានរៀល ស្មើនឹង ២១,០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣

(៥) ការគ្រប់គ្រងស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស (កម្មវិធីទី៥) ចំនួន២៤ ៨៧២,៤ លានរៀល ស្មើនឹង ៤៥,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣។

**(ខ)-មន្ទីររាជធានី ខេត្ត ៖**

យោងតាមការពិនិត្យការអនុវត្តចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាឃើញថា មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំង២៥ រាជធានី ខេត្ត បានអនុវត្តចំណាយថវិកាតាមអាណត្តិបើកប្រាក់សរុបមានចំនួន ៣៣ ៦៨៥,២ លានរៀល ស្មើនឹង៥១,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង៩១,៦% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ក្នុងនោះចំណាយលើ (ក) ការទិញ (ជំពូក៦០) អនុវត្តបានចំនួន៦ ៥៨៦,៧ លានរៀល ស្មើនឹង៦៩,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង៩៧,៧% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ខ)សេវាកម្ម (ជំពូក៦១) អនុវត្តបានចំនួន៦ ០៧៦,១ លានរៀល ស្មើនឹង៣៦,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង៦៤,០% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (គ)បន្ទុកបុគ្គលិក (ជំពូក៦៤) អនុវត្ត បានចំនួន១៧ ២២១,៦ លានរៀល ស្មើនឹង៥១,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង ១១១,៧% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ឃ)អត្ថប្រយោជន៍សង្គម អនុវត្តបានចំនួន៣ ៧៩៨,០ លានរៀល ស្មើនឹង៦៤,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង៧៤,០% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ង) ជំពូក៦៣ (ពន្ធនិងអាករ) អនុវត្តបាន២,៨ លានរៀល ស្មើនឹង៣,៨% ឬស្មើនឹង២៦,៤% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

ម្យ៉ាងទៀត ដោយពិនិត្យទៅតាមចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិកា តួលេខអនុវត្តចំណាយថវិកាសរុបចំនួន៣៣ ៦៨៥,២ លានរៀល ត្រូវបានអនុវត្តដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ដូចខាងក្រោម៖

| មន្ទីររាជធានី ខេត្ត | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២៣ | កម្មវិធី ត្រីមាសទី២ | ការអនុវត្ត ត្រីមាសទី២ | %អនុ.ត្រឹមត្រីមាសទី២ ធៀបច្បា.២០២៣ | %ធៀបកម្មវិធី ត្រីមាសទី២ |
|---|---|---|---|---|---|
| បន្ទាយមានជ័យ | 4,080,300,000 | 944,915,000 | 896,983,460 | 37.84% | 94.93% |
| បាត់ដំបង | 6,657,000,000 | 1,990,203,000 | 2,747,313,133 | 66.05% | 138.04% |
| កំពង់ចាម | 4,252,700,000 | 1,020,950,000 | 986,759,772 | 41.10% | 96.65% |
| កំពង់ឆ្នាំង | 4,512,200,000 | 1,731,010,000 | 1,722,578,400 | 59.31% | 99.51% |
| កំពង់ស្ពឺ | 4,791,000,000 | 1,744,986,000 | 1,684,917,180 | 52.44% | 96.56% |
| កំពង់ធំ | 5,685,000,000 | 2,196,012,000 | 1,885,565,863 | 51.90% | 85.86% |
| កំពត | 4,326,700,000 | 1,795,700,000 | 2,013,824,680 | 63.26% | 112.1% |
| កណ្តាល | 6,516,000,000 | 2,277,949,000 | 1,848,120,878 | 53.25% | 81.13% |
| កោះកុង | 2,628,600,000 | 680,430,000 | 628,289,500 | 36.58% | 92.34% |
| ក្រចេះ | 3,902,000,000 | 1,358,000,000 | 1,152,836,205 | 53.13% | 84.89% |
| មណ្ឌលគិរី | 2,718,700,000 | 1,333,259,000 | 397,704,440 | 26.30% | 29.83% |
| រាជធានីភ្នំពេញ | 4,193,600,000 | 1,029,397,000 | 1,166,893,870 | 49.08% | 113.36% |
| ព្រះវិហារ | 2,795,900,000 | 1,013,800,000 | 779,214,160 | 44.57% | 76.9% |
| ព្រៃវែង | 4,509,200,000 | 1,453,575,000 | 1,508,347,306 | 45.33% | 103.77% |
| ពោធិ៍សាត់ | 3,993,400,000 | 3,993,400,000 | 1,791,043,969 | 60.47% | 97.23% |
| រតនគិរី | 3,112,900,000 | 1,388,678,000 | 1,399,709,500 | 64.20% | 100.79% |
| សៀមរាប | 5,797,500,000 | 1,754,508,000 | 2,269,077,700 | 51.24% | 129.33% |
| ព្រះសីហនុ | 2,968,900,000 | 1,273,210,000 | 1,033,000,970 | 49.19% | 81.13% |
| ស្ទឹងត្រែង | 3,427,100,000 | 1,604,000,000 | 1,510,701,660 | 56.86% | 94.18% |
| ស្វាយរៀង | 3,195,600,000 | 1,601,500,000 | 951,377,100 | 43.92% | 59.41% |
| តាកែវ | 6,215,300,000 | 3,060,000,000 | 2,147,464,236 | 51.58% | 70.18% |
| ឧត្តរមានជ័យ | 3,371,800,000 | 1,209,892,000 | 734,231,700 | 56.58% | 60.69% |
| កែប | 1,692,500,000 | 561,820,000 | 465,979,560 | 43.89% | 82.94% |
| ប៉ៃលិន | 2,217,900,000 | 816,631,000 | 846,168,597 | 55.49% | 103.62% |
| ត្បូងឃ្មុំ | 4,029,200,000 | 1,098,300,000 | 1,117,133,276 | 39.61% | 101.71% |

III-**បញ្ហាប្រឈម**

យោងតាមការអធិប្បាយខាងលើឃើញថា ការអនុវត្តចំណាយថវិកាប្រចាំត្រីមាសទី២ ឆ្នាំ២០២៣ សម្រេចបានល្អប្រសើរធៀបនឹងកម្មវិធីដែលបានដាក់ចេញ ដោយសារអង្គភាពថវិកាទាំងអស់អនុវត្តយល់ដឹងតាមប្រកាស សារាចរណែនាំ និងនីតិវិធីថ្មីៗ បានដាក់ចេញនាពេលកន្លងមក។

ទន្ទឹមនឹងនេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នូវតែជួបបញ្ហាប្រឈមមួយចំនួនដែលធ្វើឱ្យដំណើរការចំណាយមានការយឺតយ៉ាវខ្លះៗ ទាំងចំណាយចរន្ត និងចំណាយមូលធន ដែលបញ្ហាលំបាកទាំងនោះមានដូចជា៖

- ការផ្តល់ធានាចំណាយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភាពយឺតយ៉ាវប្រើពេលវេលាយូរ

- ការអនុវត្តកិច្ចលទ្ធកម្មមានច្រើនដំណាក់កាលប្រើពេលវេលាយូរធ្វើឱ្យយឺតយ៉ាវក្នុងការទទួលបានសម្ភារ ឧបករណ៍ផ្សេងៗ យកមកអនុវត្តសកម្មភាពការងារ
- ការផ្តល់បុរេប្រទានជូន៦០% នៃសំណើសុំធ្វើឱ្យមានការលំបាករកថវិកា៤០% ពីប្រភពផ្សេងយកមកធ្វើសកម្មភាព ការផ្តល់នេះមិនឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងរបស់ការងារ។

## IV-**ទិសដៅអនុវត្តបន្ត**

អង្គភាពថវិកានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងខិតខំអនុវត្តចំណាយថវិកាក្នុងការធ្វើសកម្មភាពការងារដើម្បីសម្រេចបានសូចនាកររបស់ខ្លួនទៅតាមកម្មវិធីចំណាយប្រចាំត្រីមាសទី៣ ឆ្នាំ២០២៣ ដែលមានទឹកប្រាក់សរុបចំនួន៦៨ ២៤៨,៧ លានរៀល ក្នុងនោះ (១)រដ្ឋបាលកណ្តាល ចំនួន៤១ ៣២៥,៧ លានរៀល (២) មន្ទីររាជធានី-ខេត្ត ចំនួន២៦ ៩២៣, លានរៀល។

## V-**សេចក្តីសន្និដ្ឋាន**

សរុបសេចក្តីមកការអនុវត្តចំណាយថវិកាតាមអាណត្តិបើកប្រាក់ប្រចាំត្រីមាសទី២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រេចបានលទ្ធផលល្អប្រសើរជាងត្រីមាសទី២ ឆ្នាំ២០២២។

ថ្ងៃសុក្រ ៣រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣

**រដ្ឋលេខាធិការ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត ឆេង គីមស៊ុន**